CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

សាកលវិទ្យាល័យស៊ីដនី

សង្ខេបសម្រាប់
គោលនយោបាយ

ឆ្នាំ ២០១១ លេខ ១០

# អភិបាលកិច្ចតាមបែបវិមជ្ឈការលើទឹកស្រោចស្រពនៅកម្ពុជា៖ ការផ្ទុះផ្ទងរវាងគោលការណ៍ និងភាពជាក់ស្តែងនៅមូលដ្ឋាន[១]

*ដោយ ជា ជូ[២] ណាំង កិរុណា[៣] Anna THOMPSON[៣]*
*Isabelle WHITEHEAD[៣] និង Philip HIRSCH[៦]*

## បញ្ហា

គោលដៅកំពូល និងការសន្មតនានានៅក្នុងគំនិតផ្តួចផ្តើមផ្អែកអភិបាលកិច្ចនៅកម្ពុជា ពាក់ព័ន្ធនឹងការអភិវឌ្ឍនឹង គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយការចូលរួម (PIMD) និងប្រតិភូកម្មការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (IMT) មិនទាន់សម្រេចបាននៅឡើយទេក្នុងការអនុវត្តជាក់ស្តែង។ សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ត្រូវបានបង្កើតឡើងក៏ពិតមែន ប៉ុន្តែការមិនបានផ្តល់ជំនួយទ្រទ្រង់ ការបណ្តុះបណ្តាល និងហិរញ្ញវត្ថុ ឲ្យបានគ្រប់គ្រាន់ និងសក្តិសម ទៅដល់អង្គភាពកើតថ្មីទាំងនេះ បានបង្កភាពមិនស៊ីគ្នារវាងសកម្មភាពជាក់ស្តែង ដែល សកបទ អាចសម្រេចបានតាមសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេសមានកម្រិតរបស់ខ្លួន ជាមួយនឹងទំហំតួនាទី និងទំនួលខុសត្រូវដែលមានចែងក្នុងអាណត្តិរបស់ សកបទ ។ ម្យ៉ាងទៀត ទស្សនៈអភិវឌ្ឍន៍ផ្អែកលើវិមជ្ឈការ វិសហមជ្ឈការ និងការចូលរួមពីមូលដ្ឋាន បានជួបឧបសគ្គនៅតាមតំបន់ជនបទដោយសារបទពិសោធន៍ក្នុងប្រវត្តិសាស្ត្រ និងបែបបទវប្បធម៌ ដែលបានចាក់ឫសជ្រៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជា។

បញ្ហាគន្លឹះទាំងពីរខាងលើ បានធ្វើឲ្យការអនុវត្តគោលនយោបាយអភិបាលកិច្ចរបស់ សកបទ ដែលល្អផូរផង់ក្នុងទ្រឹស្តីនោះ ក្លាយជាពុំមានប្រសិទ្ធភាព និងត្រូវពឹងផ្អែកខ្លាំងលើមន្ទីរជំនាញនានា គឺមិនមែនជាអង្គភាពអភិបាលកិច្ចថ្នាក់មូលដ្ឋានប្រកបដោយចីរភាព និងឯករាជ្យភាពនោះទេ។

## សារចតារ

- អភិបាលកិច្ចប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា មានគោលបំណងចំបងពីរគឺ៖ ទី១ ទឹកត្រូវចែកចាយឲ្យទៅដល់កន្លែង និងដល់មនុស្សជាគោលដៅ តាមបែបបទអាចស្មានដឹងបាន ក្នុងបរិមាណគ្រប់គ្រាន់ និងទាន់ពេលវេលា។ ទី២ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ត្រូវរចនា រៀបចំ កសាងឡើង និងថែទាំជួសជុល ដើម្បីអាចបន្តផ្តល់អត្ថប្រយោជន៍ ជួយលើកកម្ពស់ជីវភាពប្រជាជនប្រកបដោយសមធម៌។
- ក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជាដើម្បីឈានទៅអនុវត្តគោលការណ៍វិមជ្ឈការ អាចពិនិត្យឃើញតាមការបង្កើត សកបទ នៅកម្រិតប្រព័ន្ធ

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ បានតាក់តែងឡើងដោយផ្អែកលើឯកសារពិភាក្សាមួយរបស់ CDRI ស្តីពី *"អភិបាលកិច្ចតាមបែបវិមជ្ឈការលើទឹកស្រោចស្រពនៅកម្ពុជា៖ ការផ្ទុះផ្ទងរវាងគោលការណ៍ និងភាពជាក់ស្តែងនៅមូលដ្ឋាន"* ដែលចងក្រងឡើងដោយអ្នកនិពន្ធ ជា ជូ ណាំង កិរុណ និងបោះពុម្ពផ្សាយដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។

២ ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ក្នុងកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ។

៣ ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ក្នុងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន។

៦ ជាសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវមកពីមជ្ឈមណ្ឌលអូស្ត្រាលី សិក្សាធនធានទន្លេមេគង្គនៃផ្នែកភូគព្ភសាស្ត្រ នៃសាកលវិទ្យាល័យស៊ីដនី។

ធារាសាស្ត្រ។ អង្គភាពថ្នាក់មូលដ្ឋាននេះ ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តតួនាទីអភិបាលកិច្ចដ៏ចំបង ដោយសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម (PDOWRAMs) ផង និងកសិករអ្នកទទួលផលពីប្រព័ន្ធផង។

- ប្រព័ន្ធធារាសាស្ត្រនានា មានលក្ខណៈខុសប្លែកពីគ្នាទាំងផ្នែកសង្គម និងរូបវ័ន្ត។ ភាពខុសប្លែកគ្នានេះ បង្ហាញពីបទពិសោធន៍ចម្រុះទាំងជោគជ័យ និងបរាជ័យ នៃអភិបាលកិច្ច និងការគ្រប់គ្រងប្រព័ន្ធ។ ទោះជាយ៉ាងដូច្នេះ ក៏មានបញ្ហា និងបទពិសោធន៍ដូចគ្នាមួយចំនួន ដែលតែងកើតមានចំពោះប្រព័ន្ធដែលមានលក្ខណៈខុសគ្នាទាំងនេះ។
- បញ្ហាប្រឈមផ្នែកអភិបាលកិច្ចសម្រាប់ សកបទ រួមមាន ការចូលរួមពីកសិករ តម្លាភាព វិមជ្ឈការ ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) និងការឈានទៅអនុវត្តរបបហិរញ្ញវត្ថុផ្អែកលើ "អ្នកប្រើប្រាស់ត្រូវបង់ថ្លៃ"។
- កង្វះភាពស៊ីគ្នារវាងរចនាសម្ព័ន្ធអភិបាលកិច្ច និងរចនាសម្ព័ន្ធរូបវ័ន្តនៃប្រព័ន្ធធារាសាស្ត្រ ជាកត្តានាំឲ្យមានអប្រសិទ្ធភាព និងបរាជ័យនៃប្រព័ន្ធធារាសាស្ត្រ។
- ការអនុវត្តអភិបាលកិច្ចជាក់ស្តែង មិនស៊ីគ្នានឹងអាណត្តិរបស់អង្គភាពអភិបាលកិច្ចដ៏ល្អប្រសើរ ដូចក្នុងទ្រឹស្តី និងដូចមានចែងនៅក្នុងគោលនយោបាយនោះទេ។
- ការសម្របសម្រួល រវាងគោលនយោបាយអភិវឌ្ឍន៍គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ប្រកបដោយការចូលរួម (PIMD) និងការអនុវត្តគ្រប់គ្រងផ្ទាល់ ត្រូវតែធ្វើឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងវប្បធម៌ និងខាងរចនាសម្ព័ន្ធ (ឧទាហរណ៍ រចនាសម្ព័ន្ធអភិបាលកិច្ច) ដែលកំពុងជួបប្រទះបច្ចុប្បន្ន។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ បានជ្រើសរើសប្រព័ន្ធធារាសាស្ត្រចំនួន ៣ ដោយផ្អែកលើលក្ខណៈរូបវ័ន្ត និងស្ថានភាពអភិវឌ្ឍន៍របស់ប្រព័ន្ធនីមួយៗ ដើម្បីតំណាងឲ្យប្រព័ន្ធធារាសាស្ត្រជាច្រើនទៀត ក្នុងទូទាំងតំបន់ទន្លេសាប។ ប្រព័ន្ធធារាសាស្ត្រទាំង៣ គឺមានប្រព័ន្ធធារាសាស្ត្ររលួស និងស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ និងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ក្នុងខេត្តពោធិ៍សាត់។ ការសម្ភាសអ្នកពាក់ព័ន្ធ និងការពិភាក្សាតាមក្រុម ត្រូវបានធ្វើឡើងតាមខេត្តនីមួយៗ។ អ្នកពាក់ព័ន្ធរួមមាន៖ កសិករ មេភូមិ ក្រុមប្រឹក្សាឃុំ ប្រធាន សកបទ និងតំណាងមកពីមន្ទីរធនធានទឹក និងឧតុនិយម។ ការសម្ភាសទាំងឡាយដែលមានលក្ខណៈបើកចំហខុសៗគ្នា បានធ្វើឡើងក្នុងអំឡុងពេល ៤ឆ្នាំ (ឧទាហរណ៍ សម្ភាសន៍ជាមួយកសិករម្នាក់ៗ ដោយមិនមានវត្តមានរបស់មន្ត្រីរាជការ និងសម្ភាសន៍ជាក្រុម ដោយមានវត្តមានរបស់ប្រធាន សកបទ ក្រុមប្រឹក្សាឃុំ និងសមាជិកមន្ទីរធនធានទឹក និងឧតុនិយម)។ ទិន្នន័យបែបគុណភាពនេះ បានយកមកវិភាគ ដោយពិចារណាទៅតាមបរិបទដែលប្រមូលវាបាន ដើម្បីកត់សម្គាល់ និងគិតបញ្ចូលនូវឥទ្ធិពលដែលអាចកើតមានពីសម្ពាធនៃថ្នាក់លើ ចំពោះចម្លើយរបស់អ្នកឆ្លើយសម្ភាសន៍។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

### *ភាពមិនស៊ីគ្នារវាងអភិបាលកិច្ចក្នុងឧត្តមគតិ និងក្នុងការពិតជាក់ស្តែង*

រវាងប្រព័ន្ធធារាសាស្ត្រទាំង៣ សកបទ មានសកម្មភាពខ្លាំងខ្សោយខុសគ្នាគួរឲ្យកត់សម្គាល់ ប៉ុន្តែជារួម សកបទ ក្នុងប្រព័ន្ធនីមួយៗ ពុំអាចអនុវត្តតួនាទីដែលមានចែងក្នុងអាណត្តិរបស់ខ្លួនបានពេញលេញទេ។ តួនាទីធំបំផុតរបស់គណៈកម្មាធិការ សកបទ នៅក្នុងប្រព័ន្ធធារាសាស្ត្រទាំង៣ គឺធ្វើជាអ្នកសម្រុះសម្រួល។ កសិកររាយការណ៍ពីបញ្ហាទាក់ទងនឹងការបែងចែកទឹក ហេដ្ឋារចនាសម្ព័ន្ធ និងទំនាស់ផ្សេងៗ ទៅដល់គណៈកម្មាធិការ សកបទ របស់ខ្លួន។ ជារឿយៗ សកបទ ក៏រាយការណ៍បន្តទៅឲ្យមន្ទីរធនធានទឹក និងឧតុនិយម ដែលជួយគិតគូរកំណត់ពីវិធីដោះស្រាយ និងផ្តល់យោបល់ត្រឡប់ទៅឲ្យ សកបទ វិញ។ មានការលើកឡើងថា ក្នុងតួនាទីជាអ្នកសម្រុះសម្រួល សកបទ ជារឿយៗ ផ្តល់ចម្លើយតបយឺតយ៉ាវ មិនបានជាទីពេញចិត្តទេ។ តួនាទីគួរឲ្យកត់សម្គាល់ផ្សេងទៀត ដែល សកបទ បានអនុវត្ត មានការបែងចែកទឹកពីប្រឡាយមេ និងប្រឡាយរង ការដោះស្រាយទំនាស់តូចតាចរវាងកសិករក្នុងសហគមន៍ និងការងារប្រមូលថ្លៃសេវាស្រោចស្រព (ISF) (លើកលែងនៅ តំបន់ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល)។ គណៈកម្មាធិការ សកបទ មានសិទ្ធិអំណាចតិចតួចនៅក្នុងប្រព័ន្ធរបស់ខ្លួន ហើយថែមទាំងមិនបានដឹងច្បាស់ ពីទំហំសិទ្ធិអំណាចរបស់ខ្លួនទៀតផង ជាពិសេសក្នុងករណីមានជាប់ទាក់ទងនឹងក្រុមប្រឹក្សាឃុំ។ ជាលទ្ធផលគេសង្កេតឃើញថា សមាជិក សកបទ និង ក្រុមប្រឹក្សាឃុំ បានអនុវត្តនូវទំនួលខុសត្រូវត្រួតគ្នាជាច្រើន។

មន្ទីរធនធានទឹក និងឧតុនិយម ដើរតួនាទីសំខាន់មួយក្នុងការផ្តល់ ជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុមួយផ្នែកតូច ដល់ សកបទ ជាពិសេសទាក់ទងនឹងការបែងចែកទឹក។ ប៉ុន្តែ ដូចឃើញមានក្នុងករណីប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ជំនួយទ្រទ្រង់ដិតដល់របស់មន្ទីរធនធានទឹក និងឧតុនិយម មិនសុទ្ធតែជួយឲ្យ សកបទ កាន់តែឯករាជ្យឡើងនោះទេ ផ្ទុយទៅវិញ សកបទ ក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល កាន់តែមានការពឹងផ្អែកខ្លាំងឡើងលើមន្ទីរធនធានទឹក និងឧតុនិយម ហើយត្រូវពិគ្រោះយោបល់ជាមួយនាយកដ្ឋានទាំងនោះសិន មុននឹងសម្រេចចិត្តលើការបែងចែកទឹក។ លទ្ធផលស្រាវជ្រាវបង្ហាញថា ក្រៅពីកង្វះខាតធនធានជាក់ស្តែង សកបទ ត្រូវតស៊ូប្រឹងប្រែងដំណើរការ នៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចតាមបែបប្រពៃណី និងក្នុងរបបឋានានុក្រមមានមេកើយ-កូនចៅ ដែលចាក់ឫសជ្រៅក្នុងផ្នត់គំនិតប្រជាជនមូលដ្ឋាន។

## ភាពមិនស៊ីគ្នារវាងផ្នែកអភិបាលកិច្ច និងផ្នែករូបវ័ន្ត

ករណីសិក្សាលើប្រព័ន្ធធារាសាស្ត្រនីមួយៗ បង្ហាញថា តំបន់ស្ថិតក្នុងប្រព័ន្ធទាំងនោះ មានទំហំធំណាស់ បើធៀបនឹងធនធានមនុស្ស សមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនៃ សកបទ។ សកបទ ពុំមានធនធានហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលផ្នែកបច្ចេកទេសគ្រប់គ្រាន់ សម្រាប់ការជួសជុល អភិវឌ្ឍន៍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងតំបន់ប្រព័ន្ធឡើយ។ ជាឧទាហរណ៍ ប្រព័ន្ធធារាសាស្ត្រ ២ ក្នុងចំណោមប្រព័ន្ធសិក្សាទាំង ៣ មានផ្ទៃដីដល់ជាង ១០០ហិកតា រីឯ សកបទ ក្នុងប្រព័ន្ធនីមួយៗវិញ មានសមាជិកមិនដល់ ១០នាក់ផង ហើយជាក់ស្តែងសមាជិកសកម្ម ជាទូទៅមានត្រឹម ៥នាក់ ឬតិចជាងនោះទៀត។ ឯកសារគោលនយោបាយការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយការចូលរួម (PIMD) ចែងថា ក្រុមកសិករប្រើប្រាស់ទឹកមានកាតព្វកិច្ចជួយទ្រទ្រង់ សកបទ ក្នុងការដោះស្រាយបញ្ហាតូចៗ (ឧទាហរណ៍ ក្បាលស្រែនីមួយៗ និងប្រឡាយរងតូចៗចូលស្រែ)។ ប៉ុន្តែ ជារឿយៗក្រុមកសិករប្រើប្រាស់ទឹក គឺមានតែឈ្មោះប៉ុណ្ណោះ និងមិនត្រូវបានបង្កើតឡើងត្រឹមត្រូវនោះឡើយ។ សកបទ បានយកចិត្តទុកដាក់តែតិចតួច ឬមិនបានយកចិត្តទុកដាក់សោះដល់កន្លែងមួយចំនួនក្នុងប្រព័ន្ធធារាសាស្ត្រ ជាក់ស្តែងដូចនៅប៉ែកនិរតី នៃស្រុករលួស ហើយជាលទ្ធផលកសិករនៅតំបន់នោះ មានទំនុកចិត្តតិចតួចលើការប្តេជ្ញាចិត្តរបស់ សកបទ ក្នុងការគ្រប់គ្រងប្រព័ន្ធទាំងមូល។

## ការចូលរួមពីមូលដ្ឋាន

កត្តាសំខាន់បំផុត នៃជោគជ័យក្នុងការអនុវត្ត ការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយការចូលរួម (PIMD) គឺការចូលរួមពីមូលដ្ឋានក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។ ជាទូទៅ ការចូលរួមពីមូលដ្ឋានក្នុងសកម្មភាពផ្សេងៗរបស់ សកបទ ដូចជាការបោះឆ្នោត និងការជួបប្រជុំជាដើម មានកម្រិតទាប ហើយជារឿយៗមានគេប្រាប់ថា កសិករ មិនសូវជឿជាក់លើ សកបទ ថាជាអង្គភាពអភិបាលកិច្ច ដែលមានសមត្ថភាពគ្រប់គ្រាន់ សម្រាប់គ្រប់គ្រងប្រព័ន្ធនោះទេ។ ការចូលរួមក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ក៏មានកម្រិតទាបដែរ ដែលបង្ហាញថា កសិករខ្វះអារម្មណ៍ជាម្ចាស់ និងទំនួលខុសត្រូវលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ហើយកសិករខ្លះបានប្រាប់ថា ពួកគាត់ចាត់ទុកមុខងារថែទាំនេះជាតួនាទីរបស់ សកបទ។

ការរួមចំណែកបង់ថ្លៃសេវាស្រោចស្រព ប្រែប្រួលខ្លាំងទៅតាមប្រព័ន្ធនានា។ ក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល មិនមានការប្រមូលមូលនិធិនេះទេ ស្របពេលដែល ៣០% នៃគ្រួសារក្នុងប្រព័ន្ធធារាសាស្ត្ររលួស និង ១០០% នៃអ្នកទទួលផលពីប្រព័ន្ធស្ទឹងជីនិត បានចូលរួមក្នុងមូលនិធិ។ កសិករបានបញ្ចេញទស្សនៈរួមថា ពួកគេរីករាយនឹងរួមវិភាគទានបង់ថ្លៃសេវាស្រោចស្រព (ISF) ប្រសិនបើ ពួកគេទទួលបានការឆ្លើយតបនូវសំណូមពររបស់ខ្លួន និងអត្ថប្រយោជន៍ផ្ទាល់ពីការងាររបស់ សកបទ។ សម្ភាសន៍នៅក្នុងតំបន់ប្រព័ន្ធធារាសាស្ត្រ ដំណាក់អំពិល បង្ហាញថា កសិករខ្លះមិនបានយល់ដឹងពីគោលបំណងនៃការបង់ថ្លៃសេវាស្រោចស្រពទេ ដោយពួកគេគិតថាវាជាចំណាយលើការប្រើប្រាស់ទឹក ជាជាងចំណាយសម្រាប់ការអភិវឌ្ឍ ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ។

## អនុសាសន៍គោលនយោបាយ

ការផ្លាស់ប្តូរ គួរធ្វើឡើងតាមរយៈអ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន និងកម្រិតលើៗទៀត ដើម្បីកាត់បន្ថយភាពមិនស៊ីគ្នារវាងគោលការណ៍ចង់បាន និងភាពជាក់ស្តែងនៃការអនុវត្តអភិបាលកិច្ច ក៏ដូចជារវាងទំហំនៃប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធគ្រប់គ្រងជាក់ស្តែង។ ការកាត់បន្ថយភាព

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh


មិនស៊ីគ្នានេះ នឹងនាំឲ្យមានកំណើនផលិតភាពកសិកម្ម ជីវភាពល្អប្រសើរឡើង និងការរីកចម្រើនលឿន ឈានទៅសម្រេចគោលដៅអភិវឌ្ឍធារាសាស្ត្រ និងកាត់បន្ថយភាពក្រីក្រ។

## នៅកម្រិតមូលដ្ឋាន

- ធ្វើសមាហរណកម្ម សកបទ ទៅក្នុងរចនាសម្ព័ន្ធអំណាចដែលមានស្រាប់នៅក្នុងសហគមន៍ តាមរយៈការតែងតាំង ប្រធានក្រុម មេភូមិ និងក្រុមប្រឹក្សាឃុំ (ឧទាហរណ៍ ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានមានស្រាប់) ឬការតែងតាំងអ្នកដឹកនាំជាប្រពៃណី (ឧទាហរណ៍ អាចារ្យ អតីតអ្នកដឹកនាំក្នុងរដ្ឋបាលមូលដ្ឋាន ចាស់ទុំ) និងបុគ្គលអ្នកហ៊ាននិយាយស្តី និងមានគុណសម្បត្តិផ្នែកដឹកនាំ ឲ្យចូលបម្រើការក្នុង សកបទ ដើម្បីដើរឲ្យស្របតាមទំនាក់ទំនងមេកើយ-កូនចៅ ដែលបានចាក់ឫសជ្រៅនៅក្នុងវប្បធម៌កម្ពុជា។
- ប្រមូលកសិករ ឲ្យជួយចូលរួមបង្កើតក្រុមកសិករប្រើប្រាស់ទឹក ដើម្បីចូលរួមជាមួយ សកបទ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រឱ្យមានដំណើរការល្អ។
- បន្ថយទំហំដែនគ្រប់គ្រង ឬបង្កើនទំហំ សកបទ ដោយទទួលយកតំណាងមកពីភូមិ និងឃុំផ្សេងៗនៅក្នុងប្រព័ន្ធ។
- អនុវត្តការផ្សព្វផ្សាយកាន់តែខ្លាំងក្លា និងទូលំទូលាយនូវចំណេះដឹងស្តីពី ទំនួលខុសត្រូវ និងសិទ្ធិរបស់កសិករ ទាក់ទិននឹងប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងប្រព័ន្ធ ដូចមានចែងក្នុងគោលនយោបាយការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយការចូលរួម (PIMD) ដើម្បីបណ្តុះអារម្មណ៍ជាម្ចាស់ និងឆន្ទៈចូលរួមចំណែករបស់កសិករ។
- បង្កើនការផ្សព្វផ្សាយចំណេះដឹងស្តីពី គោលដៅ និងភាពចាំបាច់ នៃការចូលរួមបង់ថ្លៃសេវាស្រោចស្រពពីសំណាក់កសិករទាំងអស់គ្នា។
- បង្កើនទំនាក់ទំនងក្រៅផ្លូវការរវាង សកបទ និងកសិករ ដើម្បីបង្កើនទំនុកចិត្តលើអង្គភាពអភិបាលកិច្ច និងសមត្ថភាពផ្នែកសង្គមកិច្ចក្នុងប្រព័ន្ធ។

## នៅកម្រិតក្រោមជាតិ (រាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាល)

- ពង្រឹងការរៀបចំយុទ្ធសាស្ត្រចាកចេញ បែបប្រាកដនិយមរបស់ម្ចាស់ជំនួយនៅពេលផ្តើមគម្រោង ដើម្បីធានាចីរភាពគម្រោង ក្រោយពេលអស់មូលនិធិពីម្ចាស់ជំនួយ។
- ធ្វើឯកជនភាវូបនីយកម្មផ្នែករដ្ឋបាល តាមរយៈការលើកទឹកចិត្ត ការបង្កើតច្បាប់ និងការពង្រឹងឲ្យមានការចូលរួម និងការប្តេជ្ញាចិត្តពីអង្គភាពអភិបាលកិច្ចនៅកម្រិតស្រុក និងខេត្ត ក្នុងការសម្របសម្រួលរវាងប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងបញ្ហានានាទាក់ទងនឹងការចែកចាយទឹកនៅដែនរងទឹកភ្លៀង (ឧទាហរណ៍ រវាងអ្នកប្រើប្រាស់នៅខ្សែទឹកខាងលើ និងខ្សែទឹកក្រោម)។ ការចូលរួមជាមួយប្រព័ន្ធរដ្ឋបាលធំទូលាយនេះ ត្រូវរៀបចំជាដំណើរការរយៈពេលវែងសម្រាប់ជម្រុញការផ្លាស់ប្តូរជាលក្ខណៈស្ថាប័ន នៅក្នុងប្រព័ន្ធរដ្ឋាភិបាល។
- អនុវត្តការផ្សព្វផ្សាយកាន់តែធំទូលាយ នូវចំណេះដឹងស្តីពី លក្ខណៈធារាសាស្ត្រក្នុងមូលដ្ឋានជូនដល់ សកបទ និងអាជ្ញាធរមូលដ្ឋានដទៃទៀត ដើម្បីជម្រុញការបែងចែកទឹកប្រកបដោយប្រសិទ្ធភាព សម្រាប់កសិកម្ម និងគ្មានការខូចខាតដល់បរិស្ថាន។

## នៅកម្រិតជាតិ

- ត្រូវពិចារណាពីការតម្រឹមគោលនយោបាយ និងការសម្របសម្រួលមន្ទីរជំនាញផ្សេងៗគ្នា ពីព្រោះទឹកជាបញ្ហាស្មុគស្មាញ ដែលមានជាប់ទាក់ទងទាំងផ្នែករូបវន្តសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ចំណុចនេះធ្វើឲ្យរបៀបគ្រប់គ្រងទឹកត្រូវពាក់ព័ន្ធច្រើនវិស័យ និងមានលក្ខណៈស្មុគស្មាញជាងការធ្លាប់គិត នៅពេលគេធ្វើសេចក្តីព្រាងអំពី គោលនយោបាយអភិបាលកិច្ចបច្ចុប្បន្ននេះ។